		61057	ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស	15,300,000	15,300,000	6,000,000	9,300,000	1,500,000	39.22%
	6107		**សោហ៊ុយសិក្សាពិសោធន៍, សោហ៊ុយនៃការប្រើ-ប្រាស់សេវា, សោហ៊ុយនៃការប្រើប្រាស់សិទ្ធិនិងសំណងផ្សេងៗ**	**80,000,000**	**80,000,000**	**17,000,000**	63,000,000	**4,250,000**	**21.25%**
		61071	សោហ៊ុយសិក្សាពិសោធន៍	80,000,000	80,000,000	17,000,000	63,000,000	4,250,000	21.25%
	6108		**សោហ៊ុយដឹកជញ្ជូន**	**6,300,000**	**6,300,000**	**3,000,000**	3,300,000	**750,000**	**47.62%**

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៩	ឥណទាន ដែល ជ្រើសរើស	ឥណទាន ផ្ទេរទៅឲ្យបុរេប្រទាន	ឥណទាន ទូទាត់ធម្មតា	ឥណទានទទួលបាន ផ្ទេរទៅឲ្យបុរេប្រទាន	ភាគរយ
				១	២	៣	៤=២-៣	៥=៣/៤	៦=៣/២
		61081	សម្ភារ និងទំនិញ	6,300,000	6,300,000	3,000,000	3,300,000	750,000	47.62%
	6110		**ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ**	**71,600,000**	**71,600,000**	**16,900,000**	**54,700,000**	**4,225,000**	**23.60%**
		61101	សោហ៊ុយទទួលភ្ញៀវជាតិ	10,000,000	10,000,000	3,000,000	7,000,000	750,000	30.00%
		61102	សោហ៊ុយទទួលភ្ញៀវបរទេស	20,000,000	20,000,000	3,000,000	17,000,000	750,000	15.00%
		61103	ប្រជុំ សិក្ខាសាលា និងសន្និសីទ	21,700,000	21,700,000	4,000,000	17,700,000	1,000,000	18.43%
		61104	ចំណាយរៀបចំពិធីបុណ្យ	15,000,000	15,000,000	2,000,000	13,000,000	500,000	13.33%
		61105	ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍ នៅក្នុងនិងក្រៅប្រទេស	4,900,000	4,900,000	4,900,000	-	1,225,000	100.00%
	6111		**សារព័ត៌មាន និងឯកសារ**	**21,900,000**	**21,900,000**	**7,000,000**	**14,900,000**	**1,750,000**	**31.96%**
		61111	ចំណាយលើការជាវសារព័ត៌មាន	5,400,000	5,400,000	2,000,000	3,400,000	500,000	37.04%
		61112	ចំណាយលើការជាវទស្សនាវដ្ដី	16,500,000	16,500,000	5,000,000	11,500,000	1,250,000	30.30%
	6112		**សោហ៊ុយបេសកកម្មក្នុងប្រទេស**	**159,000,000**	**159,000,000**	**159,000,000**	**-**	**39,750,000**	**100.00%**
		61121	សោហ៊ុយដឹកជញ្ជូន	27,700,000	27,700,000	27,700,000	-	6,925,000	100.00%
		61122	សោហ៊ុយបេសកកម្ម	18,600,000	18,600,000	18,600,000	-	4,650,000	100.00%
		61123	សោហ៊ុយស្នាក់នៅ	112,700,000	112,700,000	112,700,000	-	28,175,000	100.00%
	6113		**សោហ៊ុយបេសកកម្មក្រៅប្រទេស**	**113,200,000**	**113,200,000**	**113,200,000**	**-**	**28,300,000**	**100.00%**
		61131	សោហ៊ុយដឹកជញ្ជូន	16,200,000	16,200,000	16,200,000	-	4,050,000	100.00%
		61132	សោហ៊ុយបេសកកម្ម	26,800,000	26,800,000	26,800,000	-	6,700,000	100.00%
		61133	សោហ៊ុយស្នាក់នៅ	70,200,000	70,200,000	70,200,000	-	17,550,000	100.00%
	6114		**សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍**	**55,000,000**	**3,400,000**	**3,400,000**	**-**	**850,000**	**100.00%**
		61141	សោហ៊ុយប្រៃសណីយ៍	3,400,000	3,400,000	3,400,000	-	850,000	100.00%
		61142	សោហ៊ុយទូរគមនាគមន៍	51,600,000	-	-	-	-	-
62			**អត្ថប្រយោជន៍សង្គម**	**243,300,000**	**14,700,000**	**14,700,000**	**-**	**3,675,000**	**100.00%**
	6202		**ជំនួយសង្គមដល់ប្រជាពលរដ្ឋ**	**91,600,000**	**8,000,000**	**8,000,000**	**-**	**2,000,000**	**100.00%**
		62025	អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងប្រទេស	83,600,000	-	-	-	-	-
		62027	សំណងខូចខាតដោយសារឧបទ្ទវហេតុសាធារណៈ	8,000,000	8,000,000	8,000,000	-	2,000,000	100.00%
	6203		**ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និងវប្បធម៌**	**6,700,000**	**6,700,000**	**6,700,000**	**-**	**1,675,000**	**100.00%**
		62034	ឧបត្ថម្ភកាកបាទក្រហម	4,000,000	4,000,000	4,000,000	-	1,000,000	100.00%
		62035	ឧបត្ថម្ភសហគមន៍ កីឡា និងវប្បធម៌	700,000	700,000	700,000	-	175,000	100.00%

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ	ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៩	ឥណទាន ដែល ជ្រើសរើស	ឥណទាន ផ្ទេរទៅឲ្យបុរេប្រទាន	ឥណទាន ទូទាត់ធម្មតា	ឥណទានទទួលផ្ទេរ ផ្ទេរទៅឲ្យបុរេប្រទាន	ភាគរយ
				១	២	៣	៤=២-៣	៥=៣/៤ជុំ	៦=៣/២
		62038	ឧបត្ថម្ភដល់អង្គភាពផ្សេងៗទៀត	2,000,000	2,000,000	2,000,000	-	500,000	100.00%
	6206		**ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ចនិងវប្បធម៌**	145,000,000	-	-	-	-	-
		62061	ចំណាយលើការប្រឡង-ប្រឡងប្រជែង	145,000,000	-	-	-	-	-

បានឃើញ និងពិនិត្យត្រឹមត្រូវ

ថ្ងៃស្អៃ ៣កើត ខែ ទុតិយាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៩

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា

អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ

បណ្ឌិត វង្ស ប៊ុនឥន្ទ្រាវុធ

បានឃើញ និងពិនិត្យត្រឹមត្រូវ

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ ពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩

ជ.ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា

អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា

ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ

អមក្រសួងអប់រំ យុវជន និងកីឡា

គិន-កោសល្ល

បានឃើញ និងពិនិត្យត្រឹមត្រូវ

ថ្ងៃ ចន្ទ ១៣កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

បាត់ដំបង ថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ២០១៩

ប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

អ៊ុច-ឡឿន

បាត់ដំបង ថ្ងៃទី១៧ ខែ មិថុនា ឆ្នាំ ២០១៩

រដ្ឋលេខាធិការរងប្រធាន

ចាន់-សុខា

បានឃើញ និងឯកភាព

ថ្ងៃស្អៃ ៣កើត ខែ ទុតិយាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៩

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព

ថ្ងៃពុធ ១៥កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

បាត់ដំបង ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៩

សាកលវិទ្យាធិការស្តីទី

ប៊ិន សុំ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៧៣ សហវ.ប្រក

ប្រកាសអន្តរក្រសួង
ស្តីពី
ការបង្កើតរង្វាន់ចំណូលសម្រាប់ឆ្នាំ២០១៩
នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

****

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៨/០១៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា២៦, មាត្រា២៧, មាត្រា២៨, និងមាត្រា២៩ និងបំពេញបន្ថែមមាត្រា២៩ស្ទួន នៃអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៦២២ សហវ.អថ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៨ ស្តីពីការប្រគល់កាតព្វកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់គ្រប់គ្រងឆ្នាំ ២០១៩
- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ១៨៩០ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីនីតិវិធីនៃការគ្រប់គ្រងរជ្ជទេយ្យចំណូលសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៧៧២ សហវ.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់រដ្ឋបាលនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សម្រេច

ប្រការ១.-

បង្កើតរជ្ជទេយ្យចំណូលនៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីប្រមូលចំណូលមិនមែនសារពើពន្ធផ្សេងៗអនុលោមតាមបទប្បញ្ញត្តិជាធរមាន។ បញ្ជីរាយប្រភេទចំណូលដែលត្រូវបង្កើតរជ្ជទេយ្យចំណូលឆ្នាំ២០១៩ មានដូចខាងក្រោម៖

- អនុគណនី ៧៣០០៥ ផលទុនប្រៃសណីយ៍ និងទូរគមនាគមន៍ ១៨៧.៣៣៥.០០០.០០០ រៀល
- អនុគណនី ៧៣០៦៦ ចំណូលពីអាជ្ញាប័ណ្ណក្នុងស្រុក ១៩.៤២០.០០០.០០០ រៀល
- អនុគណនី ៧៤០១២ ផលពីការផាកពិន័យ និងដាក់ទណ្ឌកម្ម ១០០.០០០.០០០ រៀល

ប្រការ២.-

ចំនួនទឹកប្រាក់អតិបរមាដែលអនុញ្ញាតទុកនៅក្នុងបេឡាមានកំណត់ត្រឹមចំនួន ២.០០០.០០០ រៀល (ពីរលានរៀលគត់)។

ប្រការ៣.-

ប្រកាសទាំងឡាយណា ដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

ប្រការ៤.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គាធិការ និងអគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍មានភារកិច្ចទទួលបន្ទុកអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៩

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ត្រាំ អ៊ីវតឹក

ចម្លងជូនៈ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ: ០៤៧ ប្រក.កពជ.

ប្រកាស

ស្តីពី

ការផ្លាស់ប្តូរសមាសភាពក្រុមការងារស្រាវជ្រាវនៃក្រុមប្រឹក្សាយោធា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៩១អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា
- បានឃើញអនុក្រឹត្យលេខ ១៩អនក្រ.បក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា៣ នៃអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាយោធា
- ប្រកាសលេខ ០២០ប្រក.កពជ. ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាយោធា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការពារជាតិ

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៩ អ៊ីមែល៖ generalsec@mod.gov.kh

សម្រេច

ប្រការ១ .-

ត្រូវបានផ្លាស់ប្តូរសមាសភាពក្រុមការងារស្រាវជ្រាវនៃក្រុមប្រឹក្សាយោធា ដូចមានរាយនាមខាងក្រោម៖

១-ឧត្តមសេនីយ៍ឯក **ជឹម សុខ** នាយរងសេនាធិការចម្រុះ និងជានាយកទីចាត់ការបុគ្គលិក សមាជិក

ជំនួសឧត្តមសេនីយ៍ទោ **សេខ សំណាង** នាយករងទីចាត់ការបុគ្គលិក

២-ឧត្តមសេនីយ៍ឯក **ច័ន្ទ សុភត្រ្តា** នាយកទីចាត់ការហ្សីកហ្សឺន សមាជិក

ជំនួសឧត្តមសេនីយ៍ទោ **កែវ រដ្ឋា** នាយករងទីចាត់ការហ្សីកហ្សឺន។

ប្រការ២ .-

អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន ប្រធានស្ថាប័ន មេបញ្ជាការកងឯកភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០១៩

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្តេចពិជ័យសេនា ទៀ_បាញ់

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចពិជ័យសេនា ទៀ បាញ់
- ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាននៃ ខ.ភ.ម
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ
លេខ ០៥០ សសស.ក៧៩.

សេចក្ដីសម្រេច
ស្ដីពី
ការបង្កើតគណៈកម្មការដឹកនាំធ្វើលំហាត់ និងសមយុទ្ធរវាងកងយោធពលខេមរភូមិន្ទ ជាមួយបណ្ដាប្រទេសជាមិត្ត និងការចាត់តាំងសមយុទ្ធនានា ក្នុងកងយោធពលខេមរភូមិន្ទ

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យ លេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យ លេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្ដូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការពារជាតិ

សម្រេច

ប្រការ១.-

ត្រូវបានបង្កើតគណៈកម្មការសម្រាប់ដឹកនាំធ្វើលំហាត់ និងសមយុទ្ធរវាងកងយោធពលខេមរភូមិន្ទជាមួយបណ្ដាប្រទេសជាមិត្ត និងការចាត់តាំងសមយុទ្ធនានាក្នុងកងយោធពលខេមរភូមិន្ទ ដែលមានសមាសភាពដូចខាងក្រោម ៖

... ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh

១-នាយឧត្តមសេនីយ៍	**ឥត សារ៉ាត់**	អគ្គមេបញ្ជាការរង នាយសេនាធិការចម្រុះ នៃកងយោធពលខេមរភូមិន្ទ	ប្រធាន
២-នាយឧត្តមសេនីយ៍	**ណុប រតនា**	អគ្គមេបញ្ជាការរង មេបញ្ជាការ បញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាន	អនុប្រធាន
៣-ឧត្តមសេនីយ៍ឯក	**ពេជ្រ ឈឿន**	អគ្គនាយករងអគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ	អនុប្រធាន
៤-ឧត្តមសេនីយ៍ឯក	**ច័ន្ទ សុភក្ត្រា**	នាយរងសេនាធិការចម្រុះ នាយក ទីចាត់ការហ្វឹកហ្វឺន	អនុប្រធាន
៥-ឧត្តមសេនីយ៍ឯក	**ខឹមជា សារយឿន**	មេបញ្ជាការរង កងទ័ពជើងគោក	អនុប្រធាន
៦- ឧត្តមនាវីឯក	**វណ្ណា ប៊ុនលៀង**	មេបញ្ជាការរង និងជានាយសេនាធិការ កងទ័ពជើងទឹក	សមាជិក
៧- ឧត្តមសេនីយ៍ឯក	**ហែន ហឿន**	មេបញ្ជាការរង កងទ័ពជើងអាកាស	សមាជិក
៨-ឧត្តមសេនីយ៍ឯក	**ប៉ែន ផលពិសិដ្ឋ**	អគ្គលេខាធិការរង ក្រសួងការពារជាតិ	សមាជិក
៩-ឧត្តមសេនីយ៍ឯក	**ចៅ ភារិទ្ធ**	អគ្គនាយករង អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស និងជា នាយក នាយកដ្ឋានយន្តយុទ្ធ	សមាជិក
១០- ឧត្តមសេនីយ៍ឯក	**ផាត ខបុលសុភ័ក្ត្រ**	អគ្គនាយករង អគ្គនាយកដ្ឋាននយោបាយនិង កិច្ចការបរទេស និងជានាយក នាយកដ្ឋាន ទាក់ទងអន្តរជាតិ	សមាជិក
១១-ឧត្តមសេនីយ៍ឯក	**ឡាញ់ កៅ**	នាយរងសេនាធិការចម្រុះ មេបញ្ជាការ បញ្ជាការដ្ឋានរថក្រោះ អគ្គបញ្ជាការដ្ឋាន	សមាជិក
១២-ឧត្តមសេនីយ៍ឯក	**អោក ប៊ុន្នី**	នាយរងសេនាធិការចម្រុះ មេបញ្ជាការ បញ្ជាការដ្ឋានបញ្ជូនសារ អគ្គបញ្ជាការដ្ឋាន	សមាជិក
១៣-ឧត្តមសេនីយ៍ឯក	**អ៊ុល ណារ៉ាវ**	នាយរងសេនាធិការចម្រុះ មេបញ្ជាការ បញ្ជាការដ្ឋាន ការពារអាកាស អគ្គបញ្ជាការដ្ឋាន	សមាជិក
១៤-ឧត្តមសេនីយ៍ឯក	**ម៉ម សំ**	នាយរងសេនាធិការចម្រុះ នាយក ខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន	សមាជិក
១៥-ឧត្តមសេនីយ៍ឯក	**ជឹម សុខ**	នាយរងសេនាធិការចម្រុះ នាយកទីចាត់ការ បុគ្គលិក	សមាជិក
១៦-ឧត្តមសេនីយ៍ឯក	**ខឹម សន**	នាយរងសេនាធិការចម្រុះ នាយកទីចាត់ការ ឃោសនាព័ត៌មាន	សមាជិក
១៧-ឧត្តមសេនីយ៍ឯក	**ឈោស សន**	នាយរងសេនាធិការចម្រុះ នាយកទីចាត់ការ ចលនូបត្ថម្ភ	សមាជិក
១៨-ឧត្តមសេនីយ៍ឯក	**ឈឹម សារុធ**	នាយរងសេនាធិការចម្រុះ នាយកទីចាត់ការ ការពារតំបន់សាស្ត្រ	សមាជិក
១៩-ឧត្តមសេនីយ៍ឯក	**យ៉ាល់ ពិសិដ្ឋ**	នាយរងសេនាធិការចម្រុះ នាយក ទីចាត់ការបច្ចេកទេស	សមាជិក
២០-ឧត្តមសេនីយ៍ឯក	**សេន គូម៉ារី**	នាយរងសេនាធិការចម្រុះ នាយកទីចាត់ការ សុខាភិបាល	សមាជិក

២១-ឧត្តមសេនីយ៍ឯក	**អ៊ុំ**	**វណ្ណី**	នាយរងសេនាធិការចម្រុះ នាយលេខាធិការដ្ឋាន សេនាធិការចម្រុះ	សមាជិក
២២-ឧត្តមសេនីយ៍ឯក	**ម៉ម**	**យឿន**	នាយរងសេនាធិការចម្រុះ នាយកវិទ្យាស្ថានទ័ពជើងគោក	សមាជិក
២៣-ឧត្តមសេនីយ៍ឯក	**ម៉ៅ**	**សុផាន់**	មេបញ្ជាការរង កងទ័ពជើងគោក មេបញ្ជាការ កងពលតូចថ្មើរជើងលេខ៧០	សមាជិក
២៤- ឧត្តមសេនីយ៍ឯក	**ចាប**	**ភក្តី**	មេបញ្ជាការរង កងទ័ពជើងគោក មេបញ្ជាការ កងពលតូចទ័ពពិសេសឆត្រយោង ៩១១	សមាជិក
២៥-ឧត្តមសេនីយ៍ឯក	**អ៊ួន**	**សារឿន**	មេបញ្ជាការរង កងទ័ពជើងគោក	សមាជិក
២៦- ឧត្តមសេនីយ៍ឯក	**គួច**	**ស៊ីភន**	មេបញ្ជាការរង កងរាជអាវុធហត្ថ លើផ្ទៃប្រទេស	សមាជិក
២៧- ឧត្តមសេនីយ៍ឯក	**ហួត**	**សាធ្មាន**	មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស	សមាជិក
២៨- ឧត្តមសេនីយ៍ឯក	**តាំង**	**វណ្ណា**	នាយកមជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា	សមាជិក
២៩- ឧត្តមសេនីយ៍ទោ	**កុយ**	**សុផល**	មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន	សមាជិក
៣០-ឧត្តមសេនីយ៍ទោ	**មាស**	**ស៊ីណា**	អគ្គនាយករង អគ្គនាយកដ្ឋាន នយោបាយ និងកិច្ចការបរទេស	សមាជិក
៣១- ឧត្តមសេនីយ៍ទោ	**នឹម**	**ច្បាំឡេន**	នាយក ទីចាត់ការកលយុទ្ធ	សមាជិក
៣២- ឧត្តមសេនីយ៍ទោ	**កុសល**	**សុវណ្ណចន្ទសោភ័ណ**	នាយក នាយកដ្ឋាន បញ្ជូនសារ	សមាជិក
៣៣-ឧត្តមសេនីយ៍ទោ	**តាំង**	**ច័ន្ទពន្លឺ**	នាយកនាយកដ្ឋានផែនការប្រតិបត្តិការ និងហ្វឹកហ្វឺន មជ្ឈមណ្ឌលជាតិ គ្រប់គ្រងកម្លាំងរក្សាសន្តិភាព	សមាជិក
៣៤-ឧត្តមសេនីយ៍ទោ	**ខៀវ**	**សារ៉ាត់**	ជំនួយការសម្តេចពិជ័យសេនា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ	សមាជិក
៣៥-ឧត្តមសេនីយ៍ទោ	**អ៊ុក**	**សារឹម**	នាយករងទីចាត់ការហ្វឹកហ្វឺន	សមាជិក
៣៦-ឧត្តមសេនីយ៍ទោ	**ជិន**	**សារឿន**	នាយករងទីចាត់ការហ្វឹកហ្វឺន	សមាជិក
៣៧-ឧត្តមសេនីយ៍ទោ	**ណឹម**	**សុខសោភ័ណ**	នាយសេនាធិការ រង កងរាជអាវុធហត្ថ លើផ្ទៃប្រទេស	សមាជិក
៣៨- ឧត្តមសេនីយ៍ទោ	**ប៉ែន**	**សុក្រឹត្យវឌ្ឍនា**	នាយរងលេខាធិការដ្ឋាន សេនាធិការចម្រុះ	សមាជិក
៣៩- ឧត្តមសេនីយ៍ទោ	**ម៉ី**	**សារុន**	នាយរងលេខាធិការដ្ឋាន សេនាធិការចម្រុះ	សមាជិក
៤០-ឧត្តមសេនីយ៍ទោ	**ថោង**	**សុលីម៉ូ**	នាយករងទីចាត់ការឃោសនាពត៌មាន	សមាជិក

ប្រការ២.~

គណៈកម្មការនេះមានភារកិច្ច ៖

- ធ្វើជាសេនាធិការឲ្យក្រសួងការពារជាតិ ក្នុងការដឹកនាំធ្វើលំហាត់ និងសមយុទ្ធរវាងកងយោធពលខេមរភូមិន្ទជាមួយបណ្តាប្រទេសជាមិត្ត និងការចាត់តាំងលំហាត់ ឬសមយុទ្ធនានា របស់កងយោធពលខេមរភូមិន្ទ
- រៀបចំផែនការធ្វើលំហាត់ និងសមយុទ្ធ ដើម្បីដាក់ជូនក្រសួងការពារជាតិពិនិត្យសម្រេច
- ចាត់ចែងរៀបចំ និងដឹកនាំបញ្ជាចំពោះលំហាត់ និងសមយុទ្ធតាមផែនការ របស់ក្រសួងការពារជាតិ

- ប្រជុំពិភាក្សាជាមួយបណ្តាប្រទេសជាមិត្ត និងស្ថាប័នពាក់ព័ន្ធ ស្តីពីខ្លឹមសារ ទីកន្លែង ពេលវេលា និងការងារផ្សេងៗ ដើម្បីរាយការណ៍ និងសុំគោលការណ៍ទៅក្រសួងការពារជាតិសម្រេច
- ធ្វើការបូកសរុបដកពិសោធន៍ នៃការធ្វើលំហាត់ និងរាយការណ៍ជូនក្រសួងការពារជាតិ
- អនុប្រធាន និងសមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញ និងការអនុវត្តភារកិច្ចតាមការប្រគល់របស់ប្រធានគណៈកម្មការ
- គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់សេនាធិការចម្រុះ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទក្នុងការទំនាក់ទំនងការងារ
- គណៈកម្មការនេះមានសិទ្ធិបង្កើតក្រុមការងារ ដើម្បីជួយធ្វើការងារតាមការចាំបាច់ ។

ប្រការ៣.-

សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤.-

អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន នាយក នាយកដ្ឋាន ប្រធានស្ថាប័ន មេបញ្ជាការកងឯកភាព ដែលមានការពាក់ព័ន្ធនិងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ៧រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០១៩

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្តេចពិជ័យសេនា ទៀ-បាញ់

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ថ្នាក់ដឹកនាំក្រសួងការពារជាតិ
- ខុទ្ទកាល័យ សម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចពិជ័យសេនា ទៀ បាញ់
- ខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :.១០០.កសយ.ប្រក/១៩

ប្រកាស

ស្តីពី

ការបញ្ចូលក្របខណ្ឌមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ១០៨ ប្រក.ធទឧ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៩ របស់ក្រសួងធនធានទឹក និងឧតុនិយម ស្តីពីការផ្ទេរក្របខណ្ឌមន្ត្រីរាជការ

<u>សម្រេច</u>

<u>ប្រការ ១</u> - ត្រូវបានបញ្ចូលក្របខណ្ឌលោក **កាអុន សុបញ្ញារិទ្ធ** ដែលបានផ្ទេរពីក្របខណ្ឌក្រសួងធនធានទឹក និងឧតុនិយម ឲ្យមកបម្រើការងារក្នុងក្របខណ្ឌក្រសួងយុត្តិធម៌ និងចាត់ឲ្យទៅបម្រើការងារនៅនាយកដ្ឋានជំនួយទៅវិញទៅមកក្នុងវិស័យរដ្ឋប្បវេណី នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី។

<u>ប្រការ ២</u> - ប្រាក់បៀវត្ស និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់សាមីខ្លួន ត្រូវបើកនៅអង្គភាពថ្មី បន្ទាប់ពីបានផ្តាច់ចេញពីបញ្ជីបើកប្រាក់របស់អង្គភាពដើម។

<u>ប្រការ ៣</u> - នាយកខុទ្ទកាល័យ, អគ្គលេខាធិការ នៃក្រសួងយុត្តិធម៌, អគ្គនាយកកិច្ចការរដ្ឋប្បវេណី, ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក, ប្រធាននាយកដ្ឋានជំនួយទៅវិញទៅមកក្នុងវិស័យរដ្ឋប្បវេណី, ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៩

រដ្ឋមន្ត្រី

អង្គ វង្ស វឌ្ឍនា

កន្លែងទទួល ៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងមុខងារសាធារណៈ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ១០១ កយ.ប្រក/១៩

ប្រកាស

ស្ដីពី

ការចូលបម្រើការងារវិញរបស់មន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.គគ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការដាក់មន្ត្រីរាជការស៊ីវិលឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- បានឃើញអនុក្រឹត្យលេខ ២៨០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ១៥៩ កយ.ប្រក/១៨ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងយុត្តិធម៌ ស្ដីពីការដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ
- បានឃើញលិខិតលេខ ១៣ ប.ល/១៩ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ របស់នាយកដ្ឋានកិច្ចការបុគ្គលិក

សម្រេច

ប្រការ ១ - ត្រូវបានអនុញ្ញាតឲ្យលោក **អ៊ី ភាព** អត្តលេខ១៧១០២០០០៣៨ និងលោក **មិន ណារុំ** អត្តលេខ១៦៩២១០០០១៨ ជាមន្ត្រីបម្រើការងារនៅនាយកដ្ឋានកិច្ចការបុគ្គលិក នៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ចូលបម្រើការងាររបស់ខ្លួនវិញ ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ តទៅ។

ប្រការ ២ - សិទ្ធិទទួលប្រាក់បៀវត្ស ឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់ និងអតីតភាពការងារសម្រាប់សោធននិវត្តន៍របស់សាមីខ្លួន ត្រូវគិតបន្តវិញ ចាប់ពីថ្ងៃដែលបានកំណត់ក្នុងប្រការ ១។

ប្រការ ៣ - នាយកខុទ្ទកាល័យ, អគ្គលេខាធិការ នៃក្រសួងយុត្តិធម៌, ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក, ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៩

រដ្ឋមន្ត្រី

អង្គ វង្ស វឌ្ឍនា

កន្លែងទទួល ៖

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ក្រសួងមុខងារសាធារណៈ

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៣ "ដើម្បីមុខការ"

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ: ១០៧ ភ.យ.ប្រក/១៩

ប្រកាស

ស្ដីពី

ការលុបឈ្មោះមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ២០១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្ដីពីការកែសំរួលការកំណត់ប្រាក់ឧបត្ថម្ភលើកដំបូងម្ដងគត់ ជូនមន្ត្រីរាជការស៊ីវិល ចៅក្រម និងព្រះរាជអាជ្ញា ដែលចូលនិវត្តន៍ ចូលបាត់បង់សម្បទាវិជ្ជាជីវៈ មរណភាព សុំលាឈប់ពីការងារ សុំចូលនិវត្តន៍មុនកាលកំណត់ និងមិនគ្រប់ល័ក្ខខ័ណ្ឌចូលនិវត្តន៍ ឬចូលបាត់បង់សម្បទាវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២៨០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញលិខិតលេខ ១៤ ប.ល/១៩ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ របស់នាយកដ្ឋានកិច្ចការបុគ្គលិក ស្ដីពីសំណើសុំលុបឈ្មោះមន្ត្រីរាជការចំនួន ១ រូប ចេញពីក្របខណ្ឌក្រសួងយុត្តិធម៌
- បានឃើញសេចក្ដីចម្លងសំបុត្រមរណភាពលេខ ១៨ ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ របស់សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

សម្រេច

ប្រការ ១ - ត្រូវបានលុបឈ្មោះលោក **កាន់ សារី** អត្តលេខ១៨៦១២០០៣១០ ជាអនុប្រធានការិយាល័យ នៃនាយកដ្ឋានកិច្ចការអយ្យការ និងកិច្ចការអនុវត្តទោស ចេញពីក្របខណ្ឌក្រសួងយុត្តិធម៌ ចាប់ពី**ថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៩** តទៅ មូលហេតុដោយសាមីខ្លួនទទួលមរណភាព។

ប្រការ ២ - នាយកខុទ្ទកាល័យ, អគ្គលេខាធិការ នៃក្រសួងយុត្តិធម៌, ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក, ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៩

រដ្ឋមន្ត្រី

អង្គ វង្ស វឌ្ឍនា

កន្លែងទទួល ៖
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងមុខងារសាធារណៈ "ដើម្បីជូនជ្រាប"
- ដូចប្រការ ២ "ដើម្បីមុខការ"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

មហាវិថីសម្ដេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :.១០៣...កយ.ប្រក/១៩

ប្រកាស
ស្តីពី
ការលុបឈ្មោះមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ០៧៥ កយ.ប្រក/១៩ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងយុត្តិធម៌ ស្តីពីការបន្តធ្វើកម្មសិក្សារបស់មន្ត្រីរាជការ
- បានឃើញប្រកាសលេខ ០៣២ កយ.ប្រក/១៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងយុត្តិធម៌ ស្តីពីការតែងតាំងសិស្សចៅក្រមជំនាន់ទី៩ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- បានឃើញពាក្យសុំរបស់សាមីខ្លួន

សម្រេច

ប្រការ ១ - ត្រូវបានលុបឈ្មោះលោក **ជឹម សុជាថា** អត្តលេខ ១៨៧១២០០២៨២ ជាមន្ត្រីគ្រប់គ្រងរដ្ឋបាលកម្មសិក្សា នៃនាយកដ្ឋានកិច្ចការបុគ្គលិក នៃអគ្គលេខាធិការដ្ឋានក្រសួងយុត្តិធម៌ ចេញពីក្របខណ្ឌក្រសួងយុត្តិធម៌ ចាប់ពី**ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩** តទៅ មូលហេតុដោយសាមីខ្លួនត្រូវបានតែងតាំងជាសិស្សចៅក្រមជំនាន់ទី៩ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

ប្រការ ២ - នាយកខុទ្ទកាល័យ, អគ្គលេខាធិការ នៃក្រសួងយុត្តិធម៌, ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក, ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៩

រដ្ឋមន្ត្រី

អង្គ វង្ស វឌ្ឍនា

កន្លែងទទួល ៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២ "ដើម្បីមុខការ"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ១០៤ កយ.ប្រក/១៩

ប្រកាស

ស្តីពី
ការដាក់មន្ត្រីរាជការ
ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.តត ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- បានឃើញអនុក្រឹត្យលេខ ២៨០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញប្រកាសលេខ ០៣២ កយ.ប្រក/១៩ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងយុត្តិធម៌ ស្តីពីការតែងតាំងសិស្សចៅក្រមជំនាន់ទី៩ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

សម្រេច

ប្រការ ១ - ត្រូវបានដាក់មន្ត្រីរាជការចំនួន **៣ រូប** នៅទីស្តីការក្រសួងយុត្តិធម៌ ឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល **២ ឆ្នាំ** គិតចាប់ពី**ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១** ដោយមូលហេតុសាមីខ្លួនត្រូវបានតែងតាំងជាសិស្សចៅក្រមជំនាន់ទី៩ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដូចមានរាយនាមខាងក្រោម ៖

ល.រ	អត្តលេខ	គោត្តនាម និងនាម	ភេទ	មុខតំណែង	អង្គភាព
១	១៨៨០៦០០១៩២	តូច មានរិទ្ធិ	ប្រុស	ប្រធានការិយាល័យ	នាយកដ្ឋានកិច្ចការច្បាប់ និងស្ថិតិរដ្ឋប្បវេណី
២	២៨៦១២០០៣៥៩	ជួន វិបុលរដ្ឋា	ស្រី	ប្រធានការិយាល័យ	នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍
៣	១៩១០៧០០៩០៣	ហែម ក្រឹស្នា	ប្រុស	មន្ត្រីគ្រប់គ្រងរដ្ឋបាល	នាយកដ្ឋានកិច្ចការបុគ្គលិក នៃសាលាជម្រះក្តី

ប្រការ ២ - សិទ្ធិទទួលប្រាក់បៀវត្ស ឡើងឋានន្តរស័ក្តិ ឬឡើងថ្នាក់ និងអតីតភាពការងារសម្រាប់សោធននិវត្តន៍របស់សាមីខ្លួន ត្រូវកាត់ផ្តាច់ក្នុងរយៈពេលដែលសាមីខ្លួនស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស។

ប្រការ ៣ - សាមីខ្លួនត្រូវដាក់ពាក្យសុំចូលបម្រើការងាររបស់ខ្លួនវិញ ឲ្យបាន **២ ខែ** មុនពេលផុតកំណត់ នៃរយៈពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស នឹងត្រូវលុបឈ្មោះចេញពីក្របខណ្ឌរបស់ក្រសួង ក្នុងករណីដែលសាមីខ្លួនមិនចូលបម្រើការងារនៅថ្ងៃបញ្ចប់ភាពទំនេរគ្មានបៀវត្ស។

ប្រការ ៤ - នាយកខុទ្ទកាល័យ, អគ្គលេខាធិការ នៃក្រសួងយុត្តិធម៌, ប្រធាននាយកដ្ឋានកិច្ចការបុគ្គលិក, ប្រធានគ្រប់អង្គភាពដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃអង្គារ ៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១៩

រដ្ឋមន្ត្រី

អង្គ វង្ស វឌ្ឍានា

កន្លែងទទួល ៖

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ក្រសួងមុខងារសាធារណៈ

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៤ "ដើម្បីមុខការ"

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

លេខ : ...៤៦ សសរ...

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២៦៨អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញលិខិតលេខ០១១សជណ/គ.ជ.អ.ប. ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)
- បានឃើញសេចក្តីណែនាំលេខ០០៣ សហវ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ស្តីពីការរៀបចំផែនការសកម្មភាពនិងថវិកាឆ្នាំ២០១៨ សម្រាប់ការអនុវត្តកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីណែនាំលេខ០២សណន ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីការពង្រឹងកិច្ចដំណើរការ

ការកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញសេចក្តីសម្រេចលេខ០៩ ស.ស.រ. ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ស្តីពីការកំណត់របៀបរបបការងារនិងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- តាមការចាំបាច់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

សម្រេច

ប្រការ១.-

ត្រូវបានបង្កើតគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលមានសមាសភាពដូចខាងក្រោម៖

១- លោកជំទាវ	**ភឿង សកុណា**	រដ្ឋមន្ត្រី	ប្រធាន
២- ឯកឧត្តម	**ថៃ នរៈសត្យា**	រដ្ឋលេខាធិការ	អនុប្រធានប្រចាំការ
៣- លោកជំទាវ	**ម៉ិញ កុសនី**	រដ្ឋលេខាធិការ	សមាជិកា
៤- ឯកឧត្តម	**ស្រី សួន**	រដ្ឋលេខាធិការ	សមាជិក
៥- ឯកឧត្តម	**ប្រាក់ សុណ្ណារ៉ា**	រដ្ឋលេខាធិការ	សមាជិក
៦- ឯកឧត្តម	**អ៊ុន ទឹម**	អនុរដ្ឋលេខាធិការ	សមាជិក
៧- ឯកឧត្តម	**ឡុង ប៉ុណ្ណាស៊ីរីវឌ្ឍ**	អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ	សមាជិក
៨- ឯកឧត្តម	**ហាប់ ទូច**	អគ្គនាយកបច្ចេកទេសវប្បធម៌	សមាជិក
៩- លោក	**អ៊ុក សុខា**	អគ្គនាយកបេតិកភណ្ឌស្តីទី	សមាជិក
១០- លោក	**ទឹម ពេញឫទ្ធ**	អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ	សមាជិក
១១- លោក	**ស៊ិន សារ៉ាឌី**	អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ	សមាជិក
១២- លោក	**សែន កុសល**	ប្រធាននាយកដ្ឋានបុគ្គលិក	សមាជិក
១៣- លោក	**ម៉ាន់ ធីរៈ**	ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ	សមាជិក
១៤- កញ្ញា	**ជា ណារិន**	ប្រធាននាយកដ្ឋានសម្ភារៈនិងបរិក្ខារ	សមាជិកា
១៥- លោក	**ស៊ីយ៉ុន សុតារិទ្ធ**	ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប	សមាជិក
១៦- លោក	**កាខ មូរ៉ាមី**	ប្រធាននាយកដ្ឋាននីតិកម្ម	សមាជិក

១៧- លោក លោកស្រី ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត សមាជិក សមាជិកា

ប្រការ២.-

គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖

- ដឹកនាំ សម្របសម្រួលកិច្ចដំណើរការនៃកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យវប្បធម៌និងវិចិត្រសិល្បៈ
- ដឹកនាំ សម្របសម្រួល និងគាំទ្រដល់ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃការងារកំណែ

ទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដែលពាក់ព័ន្ធដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- ដឹកនាំ សម្របសម្រួល និងគាំទ្រដល់អគ្គនាយកដ្ឋាន អង្គភាពចំណុះនានាក្នុងការអនុវត្តសកម្មភាពកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ស្របតាមផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- ដឹកនាំ សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យ ឬកិច្ចការជាអាទិភាពរបស់ក្រសួង
- តាមដានត្រួតពិនិត្យជាប្រចាំលើការអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួង ស្របតាមសេចក្តីសម្រេចរួមដែលបានឯកភាពគ្នា រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាមួយនឹងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ស្តីពីការអនុវត្តផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនិងបញ្ហាប្រឈមនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការរបស់ក្រសួង ដើម្បីផ្ញើជូនគ.ជ.អ.ប. តាមការកំណត់។

ប្រការ៣.-

គណៈកម្មការនេះមានរបៀបរបបការងារជាទូទៅដូចខាងក្រោម៖

- ត្រូវមានការប្រជុំជាទៀងទាត់០១ខែម្តង និងការប្រជុំតាមការចាំបាច់ ដើម្បីដឹកនាំ សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួង
- រដ្ឋមន្ត្រីជាអ្នកកោះប្រជុំ និង ជាអធិបតីនៃអង្គប្រជុំ។ ករណីរដ្ឋមន្ត្រីអវត្តមាន ត្រូវផ្ទេរសិទ្ធិទៅឱ្យរដ្ឋលេខាធិការដែលជាអនុប្រធានប្រចាំការជាប្រធានស្តីទី ហើយប្រធានស្តីទីជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំ
- រដ្ឋមន្ត្រីអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធឬតំណាងដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មការតាមការចាំបាច់។

ប្រការ៤.-

អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាននៃគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

សមាសភាពលេខាធិការដ្ឋានមានដូចខាងក្រោម៖

១- ឯកឧត្តម	**ឡុង ប៉ុណ្ណាស៊ីរីវឌ្ឍ**	អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ	ប្រធាន
២- លោក	**ចឹង ពេញឫទ្ធ**	អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ	អនុប្រធាន

៣- លោក	**ស៊ិន សារ៉ាឌី**	អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុ	អនុប្រធាន
៤- លោក	**ហាម គឹមសុន**	អគ្គនាយករងបេតិកភណ្ឌ	សមាជិក
៥- លោក	**ឯក ប៊ុនថា**	អគ្គនាយករងបច្ចេកទេសវប្បធម៌	សមាជិក
៦- លោក	**សែន កុសល**	ប្រធាននាយកដ្ឋានបុគ្គលិក	សមាជិក
៧- លោក	**ម៉ាន់ ធីរៈ**	ប្រធាននាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ	សមាជិក
៨- កញ្ញា	**ជា ណារិន**	ប្រធាននាយកដ្ឋានសម្ភារៈនិងបរិក្ខារ	សមាជិកា
៩- លោក	**ភាច ម៉ូរ៉ាមី**	ប្រធាននាយកដ្ឋាននីតិកម្ម	សមាជិកអចិន្ត្រៃយ៍
១០- លោក	**ផូ ណារិទ្ធ**	អនុប្រធាននាយកដ្ឋាននីតិកម្ម	សមាជិក
១១- កញ្ញា	**ម៉ែន សុជានី**	អនុប្រធាននាយកដ្ឋាននីតិកម្ម	សមាជិកា
១២- លោក	**កែវ ច័ន្ទកុសល**	អនុប្រធាននាយកដ្ឋាននីតិកម្ម	សមាជិក
១៣- លោក	**ហ៊ីន រិទ្ធី**	អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប	សមាជិក
១៤- លោកស្រី	**ខុម នារី**	ប្រធានការិយាល័យនៃនាយកដ្ឋាននីតិកម្ម	សមាជិកា
១៥- លោក	**ស្រី លីមហៃ**	អនុប្រធានការិយាល័យនៃនាយកដ្ឋាននីតិកម្ម	សមាជិក

ប្រការ៥.-

លេខាធិការដ្ឋាននៃគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំលើការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យវប្បធម៌និងវិចិត្រសិល្បៈជូនគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ពិនិត្យនិងសម្រេច
- ប្រមូលផ្តុំ ចងក្រង និងរៀបចំការណែនាំផ្សព្វផ្សាយលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ដំណើរការផ្ទេរមុខងារ ឬ ភារកិច្ចទៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប. លើការងារបច្ចេកទេសទូទៅដើម្បីបម្រើដល់ការងារកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- រៀបចំផែនការការងាររបស់គណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការរបស់ក្រសួង និងធ្វើរបាយការណ៍អំពីតុល្យភាពនិងលទ្ធផលការងារជូនថ្នាក់ដឹកនាំ
- សិក្សា ស្រាវជ្រាវ តាមដាន និងវាយតម្លៃលើការអនុវត្តលិខិតបទដ្ឋានគតិយុត្តដែលក្រសួងបានដាក់ចេញសម្រាប់ច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ពិនិត្យ លើកសំណើសុំការសម្រេចនូវបញ្ជីមុខងារដែលត្រូវផ្ទេរសាកល្បង ឬ អចិន្ត្រៃយ៍ទៅរដ្ឋបាលមូលដ្ឋានថ្នាក់ក្រោមជាតិ
- ធ្វើរបាយការណ៍អំពីសកម្មភាពការងារនិងចំណូលចំណាយជូនថ្នាក់ដឹកនាំ ព្រមទាំងចម្លងជូនលេខាធិការដ្ឋាន គ.ជ.អ.ប.

- អនុវត្តការកិច្ចផ្សេងៗទៀតតាមការណែនាំរបស់គណៈកម្មការដឹកនាំកំណែទម្រង់រដ្ឋបាលនិងវិសហមជ្ឈការរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

ប្រការ៦.-

រាល់សេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ៧.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិព្រះវិហារ អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិសំបូរព្រៃគុក អធិការនៃអធិការដ្ឋាន សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ប្រធានអង្គភាពក្រោមឱវាទក្រសួង លោក លោកស្រីប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១និងប្រការ៤ ត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៩

រដ្ឋមន្ត្រី

ភឿង-សកុណា

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)
- សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

"*ដើម្បីជូនជ្រាប*"

- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្ដីការគណៈរដ្ឋមន្ត្រី